ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៚

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៧ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦

# សេចក្តីណែនាំ

## ស្តីពី

## យុទ្ធនាការដោះស្រាយ ឆ្លើយតប បញ្ហាកើនកម្តៅ និងកង្វះខាតទឹកប្រើប្រាស់របស់ប្រជាជន

យោងតាមសភាពការណ៍បន្ទាន់ និងតម្រូវការចាំបាច់ សម្រាប់ការឆ្លើយតបគ្រោះមហន្តរាយ ដោយសារការប្រែប្រួលអាកាសធាតុ ធ្វើឲ្យកំដៅមានការកើនឡើងខុសប្លែកពីធម្មតា ដែលអាចមានផលប៉ះពាល់ដល់ប្រជាជនទូទៅ និងបណ្តាលឲ្យមានភាពរាំងស្ងួតធ្ងន់ធ្ងរនៅតាមតំបន់មួយចំនួន ។ កត្តាខាងលើបណ្តាលឲ្យមានការរាំងស្ងួត ការខ្វះខាតទឹកប្រើប្រាស់ប្រចាំថ្ងៃ និងអាចកើតមានជំងឺផ្សេងៗ សម្រាប់ប្រជាជន ជាពិសេស ជនចាស់ជរា ជនពិការ ស្ត្រី និងកុមារជាដើម ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ ក្រសួងសូមធ្វើការណែនាំដល់អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានជំនាញពាក់ព័ន្ធ និងប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តទាំងអស់ ត្រូវអនុវត្តនូវវិធានការណ៍ឆ្លើយតបមួយចំនួនដូចខាងក្រោម ៖

១-ត្រូវសហការដោះស្រាយ ឆ្លើយតបចំពោះបញ្ហាកង្វះខាតទឹកជូនប្រជាជននៅតាមមូលដ្ឋាន ដោយស្មារតីទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់ ។

២-សហការរាយការណ៍ជូនក្រសួងជាបន្ទាន់ អំពី ចំនួនប្រជាជន ស្ថានភាព និងទីតាំងដែលកំពុងជួបបញ្ហាកង្វះខាតទឹកប្រើប្រាស់ ។

៣-សហការរៀបចំផែនការសកម្មភាព ចុះដោះស្រាយ ឆ្លើយតបបញ្ហាកង្វះខាតទឹកប្រើប្រាស់ និងការកើតមានជំងឺផ្សេងៗ របស់ប្រជាជនជូនក្រសួង ដើម្បីតាមដាន និងដោះស្រាយជាបន្ទាន់ ។

៤-ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីផលប៉ះពាល់ និងការការពារបណ្តាលមកពីការកើនឡើងកម្តៅ ដល់សហគមន៍ សាលារៀន វត្តអារាម និងវិហារសាសនាផ្សេងៗ ។

៥-សហការត្រៀមដោះស្រាយ ឆ្លើយតបតាមគោលដៅឲ្យបានទាន់ពេលវេលា ។

៦-ឯកឧត្តមអគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានជំនាញពាក់ព័ន្ធ និងប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តទាំងអស់ មិនអនុញ្ញាតឲ្យចេញបេសកកម្មក្រៅប្រទេសក្នុងកំឡុងពេលនេះឡើយ ។

នាយកដ្ឋានជំនាញពាក់ព័ន្ធ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តទាំងអស់ត្រូវរាយការណ៍ព័ត៌មានឆ្លើយតបអំពីផលប៉ះពាល់ដែលបណ្តាលមកពីបញ្ហាការកើនកម្តៅ មកនាយកដ្ឋានសុខុមាលភាពសង្គម ដើម្បីរាយការណ៍ជូនឯកឧត្តមអគ្គនាយកបច្ចេកទេស ហើយឯកឧត្តមអគ្គនាយកបច្ចេកទេស ត្រូវរាយការណ៍ដោយផ្ទាល់ជូន ឯកឧត្តមរដ្ឋមន្ត្រី ដើម្បីក្រសួងមានមូលដ្ឋានគ្រប់



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

គ្រាន់ក្នុងការរាយការណ៍ជូន ប្រមុខរាជរដ្ឋាភិបាលពីបញ្ហាប្រឈម និងធ្វើការដោះស្រាយជូនប្រជាជនទាន់ពេលវេលា ។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានជំនាញពាក់ព័ន្ធ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តទាំងអស់ ត្រូវខិតខំអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបទាន់ពេលវេលា ។

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន:**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- សាលារាជធានី ខេត្ត
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

«ដើម្បីជូនជ្រាប»

- អគ្គនាយកដ្ឋានបច្ចេកទេស
- នាយកដ្ឋានជំនាញពាក់ព័ន្ធ
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ទាំង២៥

«ដើម្បីអនុវត្ត»

- ឯកសារ-កាលប្បវត្តិ